# ពង្សាវតារក្សត្រទី១ និង២ 1 and 2 Kings

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ កណ្ឌពង្សាវតារក្សត្រទី១និង២ គឺជាកណ្ឌតែមួយ ហើយយើងគួរតែអានកណ្ឌនេះជាមួយកណ្ឌសាំយូអែល។ កណ្ឌយ៉ូស្វេ ចៅហ្វាយ សាំយូអែល និងពង្សាវតារក្សត្រ កត់ត្រាអំពីអ៊ីស្រាអែលចាប់ពីការមកដល់ទឹកដីសន្យារហូតដល់ការបាត់បង់ទឹកដី និងការនិរទេសរបស់យូដាទៅបាប៊ីឡូន។ អ្នកនិពន្ធកណ្ឌពង្សាវតារក្សត្រទី១និង២បានប្រើឯកសារផ្សេងៗ ដើម្បីសរសេរប្រវត្តិសាស្ត្រនេះ។ គាត់និយាយអំពីឯកសារទាំងនេះខ្លះៗ ដូចជា «សៀវភៅជាពង្សាវតារនៃពួកស្តេចអ៊ីស្រាអែល និងយូដា» (១ពង្សាវតារក្សត្រ ១៤:១៩, ២៩; ២ពង្សាវតារក្សត្រ ២៤:៥)។

## សារៈសំខាន់នៃកណ្ឌពង្សាវតារក្សត្រទី១និង២ Importance of 1 and 2 Kings

កណ្ឌពង្សាវតារក្សត្រទី១និង២ សំខាន់ខ្លាំងណាស់ ពីព្រោះកណ្ឌទាំងពីរនេះកត់ត្រាអំពីប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលមួយចំនួនធំ ដែល៖

១. បង្ហាញអំពីសេចក្តីស្មោះត្រង់របស់ព្រះចំពោះសេចក្តីសន្យារបស់ទ្រង់ និងភាពមិនស្មោះត្រង់របស់អ៊ីស្រាអែល។

២. ពន្យល់អំពីមូលហេតុដែលព្រះបានបំផ្លាញព្រះវិហាររបស់ទ្រង់ផ្ទាល់ ហើយបញ្ជូនរាស្ត្ររបស់ទ្រង់ទៅក្នុងការនិរទេស។

៣. ផ្តល់ជីវៈប្រវត្តិ កាលៈទេសៈនៃហោរាជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាចាស់។ អេសាយ យេរេមា...បានប្រកាសព្រះបន្ទូលរបស់ព្រះក្នុងកំឡុងពេលប្រវត្តិសាស្ត្រ ត្រូវបានកត់ត្រានៅក្នុងកណ្ឌពង្សាវតារក្សត្រទី១និង២។ ដូច្នេះហើយបានជាកណ្ឌពង្សាវតារក្សត្រសំខាន់សំរាប់យើងក្នុងការយល់អំពីពួកហោរា។

៤. ជាមួយនឹងពួកហោរា កណ្ឌពង្សាវតារក្សត្រទី១និង២ផ្តល់សេចក្តីលំអិតអំពីផែនការរបស់ព្រះក្នុងការសង្គ្រោះមនុស្ស ដែលត្រូវបានបើកសំដែងជាលើកដំបូងនៅក្នុងកណ្ឌលោកុប្បត្តិ ហើយត្រូវបានបំពេញសំរេចតាមរយៈព្រះយេស៊ូវ។ ដូច្នេះហើយបានជាយើងគួរតែអានពង្សាវតារក្សត្រទី១និង២តាមរយៈការយល់អំពីផែនការធំនេះ។

## ប្រវត្តិសាស្ត្រដែលត្រូវបានកត់ត្រាទុកក្នុងពង្សាវតារក្សត្រទី១និង២

### History recorded in 1 and 2 Kings

កណ្ឌនេះបន្តរឿងរបស់អ៊ីស្រាអែល ចាប់ផ្តើមដោយការជំនួសដាវីឌជាស្តេច។ សាឡូម៉ូនសាងសង់វិហារនៅក្នុងយេរូសាឡិម។ រាជ្យរបស់សាឡូម៉ូនគឺជាចំនុចខ្ពស់នៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល។ បន្ទាប់ពីការសុគតរបស់សាឡូម៉ូន ប្រជាជាតិបានបែងចែក (១ពង្សាវតារក្សត្រ ១២) ជាអាណាចក្រខាងជើង ហៅថា អ៊ីស្រាអែល និងអាណាចក្រខាងត្បូង ហៅថា យូដា។ នគរបានចាប់ផ្តើមធ្លាក់ចុះនៅពេលនេះ។








ព្រះវិហារសាឡូម៉ូន




កណ្ឌនេះនិទានអំពីរឿងរបស់អាណាចក្រទាំងពីរ រហូតដល់ជនជាតិអេស៊ើរបានយកឈ្នះអាណាចក្រខាងជើង នៅពេលសាម៉ារីត្រូវបានចាប់យកនៅក្នុងឆ្នាំ៧២២ មុនគ.ស (២ពង្សាវតារក្សត្រ ១៧)។ បន្ទាប់ពីជំពូក១៧ កណ្ឌនេះនិទានអំពីប្រវត្តិសាស្ត្ររបស់យូដា រហូតដល់ក្រុងយេរូសាឡិម ត្រូវបានចាប់យក និងបំផ្លាញដោយជនជាតិបាប៊ីឡូន នៅក្នុងឆ្នាំ៥៨៧ មុនគ.ស។ រឿងនៅក្នុងពង្សាវតារក្សត្រទាំងមូលមានរយៈពេល ៥០០ ឆ្នាំ។




ស្ដេចភាគច្រើនរបស់អ៊ីស្រាអែលបានបរាជ័យ។ សូម្បីតែសាឡូម៉ូន ដែលទូលសុំប្រាជ្ញាពីព្រះ ហើយបានសាងសង់ព្រះវិហារ ក៏ធ្វើការសំរេចចិត្តដ៏ល្ងីល្ងើដែរ។ កណ្ឌនេះវាយតំលៃស្ដេចទាំងអស់តាមខ្នាតគំរូមួយថា តើទ្រង់ដើរតាម

ព្រះជាម្ចាស់ដោយស្មោះត្រង់ដែរឬទេ? តើទ្រង់សាងសង់អាសនាសំរាប់ព្រះដទៃនៅទីខ្ពស់ ឬវាយរំលំអាសនាទាំងនោះ? ចំពោះរឿងដែលស្តេចធ្វើនយោបាយល្អ ឬជាអ្នកដឹកនាំយោធាល្អ មិនសូវសំខាន់ទេ។ ស្តេចដែលបង្កើតអោយមានការថ្វាយបង្គំរូបព្រះបាននាំរាស្ត្ររបស់ពួកគេអោយវង្វេង ហើយនាំមកនូវការវិនាសនៅក្នុងអាណាចក្ររបស់ខ្លួន។

ក្នុងកំឡុងពេលនេះ ពួកហោរា ជាពិសេសអេលីយ៉ា និង អេលីសេ ទទូចអោយអ៊ីស្រាអែលរក្សាភាពស្មោះត្រង់ទៅចំពោះព្រះ។ ជាឧទាហរណ៍ តាមរយៈអេលីយ៉ា ព្រះយេហូវ៉ាបង្ហាញថា ទ្រង់គឺជាព្រះដ៏មានអំណាចព្រះចេស្តាពិត ដែលប្រទានជីវិត អាហារ និងទឹក (ជំពូក ១៧-១៨)។ ព្រះបើកសំដែងថា ទ្រង់គឺជាព្រះមួយអង្គដែលពួកគេត្រូវតែថ្វាយបង្គំ និងទុកចិត្ត។ រឿងអំពីហោរាផ្សេងៗទៀតមាននៅក្នុង១ពង្សាវតារក្សត្រ ២០និង២២។

យើងត្រូវតែចងចាំថា អ្នកនិពន្ធកណ្ឌនេះមិនគ្រាន់តែកត់ត្រាប្រវត្តិសាស្ត្រនោះទេ ប៉ុន្តែគាត់ក៏ពន្យល់អំពីមូលហេតុដែលព្រឹត្តិការណ៍ទាំងនេះបានកើតឡើង គឺផ្តល់អោយយើងនូវទស្សនៈរបស់ព្រះចំពោះព្រឹត្តិការណ៍ទាំងនេះ។

## គម្រោង Outline

រាជ្យរបស់ស្តេចសាឡូម៉ូន (១ពង្សាវតារក្សត្រ ១:១-១១:៤៣)
នគរបែងចែកជាពីរ (១ពង្សាតារក្សត្រ ១២:១-១៦:៣៤)
ហោរាអេលីយ៉ា និងអេលីសេ (១ពង្សាវតារក្សត្រ ១៧:១-២ពង្សាវតារក្សត្រ ៨:១៥)
ពួកស្តេចយូដានិងអ៊ីស្រាអែល (២ពង្សាវតារក្សត្រ ៨:១៦-១៦:២០)
ការធ្លាក់ចុះរបស់អ៊ីស្រាអែល ដែលជាអាណាចក្រខាងជើង (២ពង្សាវតារក្សត្រ ១៧:១-៤១)
យូដា ដែលជាអាណាចក្រខាងត្បូង រហូតដល់ការធ្លាក់ចុះរបស់ក្រុងយេរូសាឡិម (២ពង្សាវតារក្សត្រ ១៨:១-២៥:៣០)

## តើកណ្ឌពង្សាវតារក្សត្រត្រូវបានសរសេរឡើងនៅពេលណា?

### When were the books of Kings written?

កណ្ឌពង្សាវតារក្សត្រត្រូវបានសរសេរឡើងបន្ទាប់ពីឆ្នាំ៥៦១ មុនគ.ស។ ព្រឹត្តិការណ៍ចុងក្រោយដែលត្រូវបានកត់ត្រាទុកក្នុងកណ្ឌទាំងពីរនេះគឺស្តេចយេហូយ៉ាគីនត្រូវបានដោះលែងពីគុក ប្រហែលពាក់កណ្តាលពេលនៃការនិរទេសរបស់សាសន៍យូដាទៅក្នុងបាប៊ីឡូន។ កណ្ឌនេះមិនកត់ត្រាអំពីអ្នកនិរទេសវិលត្រឡប់មកកាន់យេរូសាឡិមក្នុងឆ្នាំ៥៣៨មុន គ.ស វិញទេ។

## របៀបអានកណ្ឌពង្សាវតារក្សត្រទី១និង២ How to read 1 and 2 Kings

កំហុសមួយដែលតែងតែកើតមានឡើងនៅពេលអានពង្សាវតារក្សត្រទី១និង២គឺ ការគ្រាន់តែអានកណ្ឌនេះជាសេចក្តីណែនាំខាងសីលធម៌ប៉ុណ្ណោះ។ នៅពេលអានកណ្ឌនេះតាមរបៀបនេះ នោះអ្នកអាចអានរឿងរបស់ស្តេចមួយអង្គ ហើយអនុវត្តរឿងនោះមកក្នុងយើងដោយផ្ទាល់ ជាមួយការអនុវត្តខាងសីលធម៌ ដែលព្រះមិនសព្វព្រះទ័យនឹងការមិនស្តាប់បង្គាប់របស់ស្តេច ឬសព្វព្រះទ័យនឹងការស្តាប់បង្គាប់របស់ស្តេច ដូច្នេះ យើងគួរតែស្តាប់បង្គាប់តាមព្រះ។ ទោះបីជា

ការពិតដែលរឿងទាំងនេះគឺជាការព្រមាន ហើយលើកទឹកចិត្តយើងអោយស្តាប់បង្គាប់តាមព្រះក៏ដោយ (១កូរិនថូស ១០:១១) ប្រសិនបើយើងអានតាមរបៀបនេះ នោះយើងបាត់បង់ព្រះរាជសារ និងការអនុវត្តចំបងនៅក្នុងកណ្ឌទាំងពីរនេះហើយ។ ប្រសិនបើយើងគ្រាន់តែនិយាយថា «យកតម្រាប់តាមស្តេចណាដែលល្អ ហើយកុំយកតម្រាប់តាមស្តេចណាដែលអាក្រក់» នោះតើវាខុសពីការដែលយើងអានរឿងរបស់ស្តេចជនជាតិខ្មែរ ហើយនិយាយថា «យកតម្រាប់តាមស្តេចល្អ មិនយកតម្រាប់តាមស្តេចអាក្រក់ទេ» ដែរឬទេ? កណ្ឌទាំងពីរនេះមានព្រះរាជសារជ្រាលជ្រៅជាងនេះទៅទៀត។ ដើម្បីយល់អំពីព្រះរាជសារនៅក្នុងកណ្ឌពង្សាវតារក្សត្រ យើងត្រូវតែយល់នៅក្នុងបរិបទរបស់ព្រះគម្ពីរទាំងមូល។ ដើម្បីយល់ យើងត្រូវឆ្លើយនឹងសំនួរប្រាំខាងក្រោម។

១. តើកណ្ឌពង្សាវតារក្សត្រទី១និង២ទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌទាំងពីរនេះ យ៉ាងដូចម្តេច?

២. តើគោលបំណងរបស់កណ្ឌពង្សាវតារក្សត្រទី១និង២សំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

៣. តើកណ្ឌពង្សាវតារក្សត្រទី១និង២ទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌទាំងពីរនេះយ៉ាងដូចម្តេច?

៤. តើកណ្ឌទាំងពីរនេះបង្រៀនយើងអ្វីអំពីព្រះ?

៥. តើកណ្ឌទាំងពីរនេះបង្រៀនយើងអ្វីអំពីមនុស្ស?

### ១. តើកណ្ឌពង្សាវតារក្សត្រទី១និង២ទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌទាំងពីរនេះយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺជារឿងធំមួយ ដែលពន្យល់អំពីផែនការរបស់ព្រះចាប់តាំងពីការបង្កបង្កើតដល់ការបង្កបង្កើតថ្មី។ ទ្រង់បានបង្កើតគ្រប់យ៉ាងល្អជាដំបូង ដោយមានអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ នេះគឺជាគោលដៅរបស់ព្រះសំរាប់ការបង្កបង្កើត។ ពួកគេមិនបានស្តាប់បង្គាប់ ហើយត្រូវបានបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ កន្លែងផ្សេងៗទាំងអស់ទៀតក្នុងព្រះគម្ពីរនិយាយអំពីផែនការរបស់ព្រះ ក្នុងការសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តានគររបស់ទ្រង់ឡើងវិញ ដែលជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយជាជាតិសាសន៍មួយដ៏ធំ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ តាមរយៈពូជពង្សរបស់អ័ប្រាហាំ ព្រះនឹងប្រទានពរដល់លោកិយ។ ពួកគេត្រូវតែជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ ។ ទ្រង់នឹងគង់ក្នុងចំណោមពួកគេ ដូច្នេះអ៊ីស្រាអែលនៅក្នុងទឹកដីសន្យាគឺអេដែនថ្មី ដែលជាទីបរិសុទ្ធថ្មី។ ព្រះបានសន្យាថា ប្រសិនបើពួកគេស្តាប់បង្គាប់ទ្រង់ នោះពួកគេនឹងបានពរហើយរស់នៅក្នុងទឹកដី ហើយប្រសិនបើពួកគេមិនស្តាប់បង្គាប់ទ្រង់ទេ នោះពួកគេនឹងត្រូវ

បណ្តាសា ហើយបណ្តេញចេញពីទឹកដីមិនខាន (ចោទិយកថា ៤:២៥-២៧, ៤០; ចោទិយកថា ២៨)។ ព្រះបានបង្គាប់ថា ពួកគេត្រូវតែថ្វាយបង្គំទ្រង់នៅទីកន្លែងមួយ ដែលទ្រង់នឹងជ្រើសរើស (ចោទិយកថា ១២:១-១៩)។

ព្រះសង្កត់ធ្ងន់ជាពិសេសលើសារៈសំខាន់នៃការស្តាប់បង្គាប់របស់ស្តេច (ចោទិយកថា ១៧:១៤-២០)។ ដាវីឌបានមានប្រសាសន៍ម្តងទៀងអំពីការសង្កត់ធ្ងន់នេះទៅកាន់សាឡូម៉ូននៅក្នុង១ពង្សាវតារក្សត្រ ២:២-៤ ហើយពេលព្រះមានបន្ទូលទៅកាន់សាឡូម៉ូន នៅពេលគាត់កំពុងសាងសង់ព្រះវិហារ (១ពង្សាវតារក្សត្រ ៦:១២) និងបន្ទាប់ពីគាត់បានបញ្ចប់ការសាងសង់ព្រះវិហារ (១ពង្សាវតារក្សត្រ ៩:៤-៩)។ សាឡូម៉ូននិយាយក្នុងសេចក្តីអធិស្ឋានថា ពួកស្តេចត្រូវតែស្តាប់បង្គាប់ដើម្បីអោយរាជ្យវង្សបន្តមាននៅ (១ពង្សាវតារក្សត្រ ៨:២៥)។

ព្រះបានធ្វើការសន្យាយ៉ាងសំខាន់មួយជាមួយស្តេចដាវីឌថា រាជ្យរបស់ដាវីឌនឹងគង់នៅជារៀងរហូត ហើយថា ពូជពង្សរបស់ទ្រង់នឹងសាងសង់ព្រះវិហាររបស់ព្រះ (២សាំយូអែល ៧:១-១៦)។ ប្រវត្តិសាស្ត្រទាំងអស់នេះផ្តល់មូលដ្ឋានគ្រឹះចាំបាច់សំរាប់ការយល់អំពីកណ្ឌពង្សាវតារក្សត្រទី១និង២។ ដូច្នេះ បទគម្ពីរគន្លឹះពីមុនកណ្ឌពង្សាវតារក្សត្រទី១និង២សំរាប់ការយល់កណ្ឌទាំងពីរនេះរួមមាន លោកុប្បត្តិ ១-៣ ; ១២:១-៧; និក្ខមនំ ១៩:៤-៦; ចោទិយកថា ១២:១-១៩; ១៧:១៤-២០; ២៨:១-៦៨ និង ២សាំយូអែល ៧:១-១៦។

## ២. តើគោលបំណងរបស់កណ្ឌពង្សាវតារក្សត្រទី១និង២សំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

ព្រះបានបង្គាប់ថា ពួកអ៊ីស្រាអែលត្រូវតែថ្វាយបង្គំទ្រង់នៅទីកន្លែងមួយ ដែលទ្រង់នឹងជ្រើសរើស (ចោទិយកថា ១២:១-១៩)។ កណ្ឌពង្សាវតារក្សត្របង្ហាញថា ព្រះជាម្ចាស់បានជ្រើសរើសយេរូសាឡិមធ្វើជាកន្លែងដែលគេត្រូវថ្វាយបង្គំព្រះអង្គ ហើយសាឡូម៉ូនបានសាងសង់វិហាររបស់ព្រះ ដើម្បីបំពេញសំរេចតាមសេចក្តីសន្យារបស់ព្រះចំពោះដាវីឌ (២សាំយ៉ូអែល ៧:១២-១៣)។ សាឡូម៉ូននិងពួកស្តេចបន្ទាប់ពីទ្រង់បានបរាជ័យធ្វើតាមសេចក្តីបង្គាប់របស់ព្រះសំរាប់ស្តេចនៅក្នុងចោទិយកថា ១៧:១៤-២០ ហើយមនុស្សបានបះបោរប្រឆាំងនឹងព្រះ ធ្វើអោយព្រះមានសេចក្តីក្រោធដោយសារតែភាពមិនស្មោះត្រង់របស់ពួកគេចំពោះសម្ព័ន្ធមេត្រីរបស់ទ្រង់ ជាពិសេសដោយគេថ្វាយបង្គំរូបព្រះ។

ដូច្នេះ ទ្រង់បានបញ្ជូនពួកគេចេញពីទឹកដីតាមការព្រមាននៅក្នុងចោទិយកថា ២៨:១៥-៦៨។ ដូចដែលមនុស្សអាចសួរថា «តើហេតុអ្វីសង្គ្រាមលោកលើកទី២បានកើតឡើង?» ឬ «តើហេតុអ្វីខ្មែរក្រហមបានកើតឡើង?» ជនជាតិអ៊ីស្រាអែលនៅពេលកណ្ឌពង្សាវតារក្សត្រទី១និង២ត្រូវបានសរសេរឡើងបានសួរថា «តើហេតុអ្វីក្រុងយេរូសាឡិមនិងវិហាររបស់ព្រះត្រូវបានបំផ្លាញ ហើយយើងត្រូវនិរទេសដូច្នេះ?»។ ទោះយ៉ាងណា ស្ថានភាពរបស់ជនជាតិអ៊ីស្រាអែលខុសពីមនុស្សនៅក្នុងសង្គ្រាមលោកលើកទី២ ឬខ្មែរក្រហម។ ជនជាតិអ៊ីស្រាអែលគឺជារាស្ត្ររបស់ព្រះ។ តើការបរាជ័យនិងការនិរទេសរបស់ពួកគេមានន័យថា ព្រះបានបោះបង់ពួកគេ ឬថា ព្រះមិនខ្លាំងគ្រប់គ្រាន់ដើម្បីការពារពួកគេ? តើព្រះរបស់បាប៊ីឡូនខ្លាំងជាងព្រះរបស់ពួកគេឬ? ព្រះបានប្រទានវិហារនិងសេចក្តីសន្យារបស់ទ្រង់ថា ពូជពង្សរបស់ដាវីឌនឹងគ្រប់គ្រងជារៀងរហូត ប៉ុន្តែវាហាក់ដូចជាព្រះមិនបានរក្សាសេចក្តីសន្យារបស់ទ្រង់ទេ។

កណ្ឌពង្សាវតារក្សត្រទី១និង២ បង្ហាញថា ការនិរទេសមិនបានកើតឡើងដោយសារតែព្រះមិនខ្លាំងគ្រប់គ្រាន់ដើម្បីការពារពួកគេ ឬព្រះរបស់បាប៊ីឡូនខ្លាំងជាងនោះទេ ប៉ុន្តែបង្ហាញថា ព្រះបានធ្វើអោយព្រឹត្តិការណ៍ទាំងនេះកើតឡើងដោយព្រោះទ្រង់បានបោះបង់ចោលរាស្ត្ររបស់ទ្រង់ ដោយសារតែពួកគេមិនស្មោះត្រង់ចំពោះព្រះ។ អ៊ីស្រាអែលបានបរាជ័យធ្វើជារាស្ត្របរិសុទ្ធ និងព្រះពរដល់លោកិយ។ ដូច្នេះ ព្រះជាម្ចាស់យុត្តិធម៌និងត្រឹមត្រូវក្នុងការនាំការវិនិច្ឆ័យទាំងនេះមកលើពួកគេ។ ពួកគេមិនអាចរអ៊ូរទាំទាស់នឹងព្រះបានទេ ព្រោះព្រឹត្តិការណ៍ទាំងនេះជាកំហុសរបស់ពួកគេ។

### ៣. តើកណ្ឌពង្សាវតារក្សត្រទី១និង២ទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌទាំងពីរនេះយ៉ាងដូចម្តេច?

អ្វីដែលយើងរៀនខាងលើនេះបង្កើតសំនួរយ៉ាងធំពីរ។ តើព្រះនឹងបោះបង់ចោលរាស្ត្ររបស់ទ្រង់ជារៀងរហូតឬ? តើមានអ្វីបានកើតឡើងចំពោះសេចក្តីសន្យារបស់ព្រះចំពោះដាវីឌ?

ដូចដែលបានលើកឡើងខាងលើហើយ កណ្ឌពង្សាវតារក្សត្រទី១និងទី២ ផ្តល់ជីវៈប្រវត្តិដល់ហោរាជាច្រើន។ ពួកហោរាចាប់ពីអេសាយមកបានប្រកាសថា ព្រះមិនបានបោះបង់ចោលរាស្ត្ររបស់ទ្រង់ទាំងស្រុងនោះឡើយ ប៉ុន្តែទ្រង់បានជ្រើសរើសពួកសេសសល់ដែលនឹងវិលត្រឡប់មកវិញ (អេសាយ ១០:២១-២២; ៣៧:៣១)។

លើសពីនេះ ព្រះមិនបានបោះបង់សេចក្តីសន្យារបស់ទ្រង់ជាមួយដាវីឌទេ ប៉ុន្តែទ្រង់នឹងលើកស្តេចមួយអង្គនៅក្នុងថ្ងៃអនាគត ជាពូជពង្សរបស់ដាវីឌ ដែលនឹងសង្គ្រោះរាស្ត្ររបស់ទ្រង់ ហើយនិងគ្រប់គ្រងលើពិភពលោកទាំងមូលអស់កល្បជានិច្ច (អេសាយ ៩:៧; ១១:១-១០; យេរេមា ២៣:៥; អេសេគាល ៣៤:២៣-២៤; ៣៧:២៤-២៥)។ ពូជពង្សរបស់ដាវីឌនេះខុសពីស្តេចរបស់អ៊ីស្រាអែលនិងយូដា ពីព្រោះស្តេចនេះគ្មានបាបសោះ ដូច្នេះទ្រង់នេះមានសិទ្ធិនិងសមត្ថភាពគ្រប់គ្រងអស់កល្បជានិច្ច។

លើសពីនេះទៅទៀត ទ្រង់នឹងទទួលយកទណ្ឌកម្មសំរាប់អំពើបាបរបស់យើង ដើម្បីអោយយើងមិនត្រូវបណ្តាសា ដូចជាអ៊ីស្រាអែលដែលត្រូវវិនាសនិងនិរទេសឡើយ (អេសាយ ៥២:១៣-៥៣:១២)។ តាមរយៈស្តេចមួយអង្គនេះ ព្រះនឹងប្រទានពរដល់លោកិយតាមរយៈពូជរបស់អ័ប្រាហាំ។ ប្រាកដណាស់ថា ស្តេចដែលនឹងយាងមកនេះគឺជាព្រះយេស៊ូវ (សូមមើលលូកា ១:៣២-៣៣)។ មនុស្សដែលបដិសេធទ្រង់នឹងត្រូវបោះបង់ចោលជារៀងរហូត (នៅពេលពួកយូដាបានសម្លាប់ព្រះយេស៊ូវគឺជាការបះបោរចុងក្រោយ ដែលនាំអោយព្រះបោះបង់ពួកគេចោលទាំងស្រុង (ម៉ាថាយ ២១:៣៣-៤៤)។ ប៉ុន្តែតាមរយៈព្រះគ្រីស្ទ ព្រះបានជ្រើសរើសពួកសេសសល់ ដែលនឹងបានសង្គ្រោះដោយសារសេចក្តីជំនឿលើទ្រង់។ ដូច្នេះ នៅពេលយើងអានកណ្ឌពង្សាវតារក្សត្រទី១និង២បានត្រឹមត្រូវ នោះយើងនឹងមើលឃើញថាកណ្ឌនេះចង្អុលទៅកាន់ព្រះយេស៊ូវ ជាស្តេចពិតប្រាកដ ដែលនឹងគ្រប់គ្រងដោយសុចរិតនៅក្នុងទីបរិសុទ្ធអស់កល្បជានិច្ច ដែលជាទីក្រុងយេរូសាឡិមថ្មី។

### ៤. តើកណ្ឌទាំងពីរនេះបង្រៀនយើងអ្វីអំពីព្រះ?

តាមរយៈការរៀបរាប់ខាងលើ យើងឃើញថា កណ្ឌពង្សាវតារក្សត្របង្រៀនថា ព្រះ

- គឺជាព្រះដ៏ពិត ហើយព្រះដទៃទាំងអស់សុទ្ធតែជាព្រះក្លែងក្លាយទាំងអស់។
- ស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់។
- បរិសុទ្ធ និងទតឃើញគ្រប់ទាំងអស់ ហើយដាក់ទណ្ឌកម្មចំពោះអំពើបាប។
- ស្អប់ការថ្វាយបង្គំរូបព្រះ។
- គ្រប់គ្រងប្រវត្តិសាស្ត្ររបស់មនុស្សជាតិដោយព្រះបន្ទូលរបស់ទ្រង់។ ព្រឹត្តិការណ៍ដែលត្រូវបានកត់ទុកនៅក្នុងពង្សាវតារក្សត្រគឺជាសកម្មភាពរបស់ព្រះ ហើយបានបំពេញសំរេចសេចក្តីសន្យានិងការព្រមានរបស់ព្រះ ដែលទ្រង់បានប្រទានអោយរាប់សតវត្សមុន។
- ប្រទានប្រាជ្ញា។
- មានបន្ទូលមកកាន់រាស្ត្ររបស់ទ្រង់ ហើយពន្យល់អំពីផែនការរបស់ទ្រង់សំរាប់លោកិយ។
- ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបានបញ្ជូនពួកហោរារបស់ទ្រង់មកឯរាស្ត្ររបស់ទ្រង់ ដើម្បីប្រាប់ពួកគេអោយប្រែចិត្ត។ ដូចគ្នាផងដែរ សព្វថ្ងៃនេះ ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបញ្ជូនគ្រីស្ទបរិស័ទទៅក្នុងលោកិយ ដើម្បីប្រកាសដំណឹងល្អអោយមនុស្សបានជឿលើព្រះយេស៊ូវ និងងាកបែរមករកទ្រង់វិញ។

## ៥. តើកណ្ឌទាំងពីរនេះបង្រៀនយើងអ្វីអំពីមនុស្ស?

- មនុស្សបះបោរប្រឆាំងនឹងព្រះ ហើយសមនឹងទទួលទណ្ឌកម្មពីទ្រង់។
- ជាធម្មតា មនុស្សព្រងើយកន្តើយចំពោះព្រះបន្ទូលរបស់ព្រះ។
- មនុស្សចូលចិត្តថ្វាយបង្គំរូបព្រះ។ យើងដើរតាមរូបព្រះដោយលឿនជាងការដើរតាមព្រះដ៏ពិត។